# ផលផ្លែរបស់ព្រះវិញ្ញាណ



## សេចក្ដីស្រឡាញ់ ἀγάπη

**ចិត្តមេត្តា ឆន្ទៈល្អ ការគោរព**

“**សេចក្ដីស្រឡាញ់** អត់ធ្មត់ សេចក្ដីស្រឡាញ់ សប្បុរស និងមិនច្រណែន សេចក្ដីស្រឡាញ់ មិនអួតខ្លួន និងមិនបំផ្លើស...”
(១កូរិនថូស ១៣:៤-៥ គគខ)

## អំណរ χαρὰ

**សេចក្ដីអរ ឬក៏ត្រេកអរដែលជាប្រភពនៃអំណរ**

“ចូរអ្នករាល់គ្នាមាន**អំណរ**ដូចគ្នា ហើយត្រេកអរជាមួយខ្ញុំដែរចុះ។”
(ភីលីព ២:១៨ គគខ)

## សេចក្ដីសុខសាន្ត εἰρήνη

**សេចក្ដីរាប់រក សេចក្ដីរាប់អាន ចិត្តដែលប្រកបដោយសន្តិភាព**

“ដ្បិតព្រះអង្គជា**សេចក្ដីសុខសាន្ត**របស់យើង...” (អេភេសូរ ២:១៤ គគខ)

## សេចក្ដីអត់ធ្មត់ μακροθυμία

**អំណត់ ខន្តី អត់ទ្រាំ ហើយមិនតួញត្អែរ**

“ប៉ុន្តែព្រះអង្គអាណិតមេត្តាដល់ខ្ញុំដូច្នេះ គឺដើម្បីឲ្យព្រះគ្រីស្ទយេស៊ូវបង្ហាញ**សេចក្ដីអត់ធ្មត់**ដ៏ពេញលេញរបស់ព្រះអង្គដល់ខ្ញុំ ដែលជាមនុស្សបាបបំផុត និងទុកជាគំរូដល់អស់អ្នកដែលនឹងជឿលើព្រះអង្គដើម្បីឲ្យបានជីវិតអស់កល្បជានិច្ច។” (១ធីម៉ូថេ ១:១៦ គគខ)

## សេចក្ដីសប្បុរស χρηστότης

**ទៀងត្រង់ សេចក្ដីករុណា ភាពផ្អែមល្ហែម**

“មិនត្រូវនិយាយបង្ខូចអ្នកណាម្នាក់ ឬរករឿងឈ្លោះប្រកែកឡើយ ត្រូវមានចិត្តស្លូតបូត ទាំងបង្ហាញចិត្តសុភាពគ្រប់បែបយ៉ាងដល់មនុស្សទាំងអស់...ប៉ុន្តែនៅពេលដែល**សេចក្ដីសប្បុរស**របស់ព្រះជាម្ចាស់...” (ទីតុស ៣:២-៥ គគខ)

## សេចក្ដីល្អ ἀγαθωσύνη

**ល្អ សន្ដានចិត្តល្អ ការចូលចិត្តធ្វើល្អ**

“ព្រោះកាលពីមុនអ្នករាល់គ្នាជាសេចក្ដីងងឹត ប៉ុន្តែឥឡូវនេះ អ្នករាល់គ្នាជាពន្លឺនៅក្នុងព្រះអម្ចាស់...ដ្បិតផលផ្លែរបស់ពន្លឺមាននៅក្នុងគ្រប់ទាំង**សេចក្ដីល្អ**...”
(អេភេសូរ ៥:៨-៩ គគខ)

## ភាពស្មោះត្រង់ πίστις

**ការជឿជាក់ ទំនុកចិត្ត ការទុកចិត្ត មិនប្រែប្រួល ភក្ដីភាព**

“នោះចូរឲ្យយើងចូលទៅជិតព្រះជាម្ចាស់ដោយចិត្ត**ស្មោះត្រង់** និងជំនឿជឿជាក់ ទាំងមានចិត្តដែលបានប្រោះសំអាតពីមនសិការអាក្រក់ និងរូបកាយដែលបានលាងសំអាតដោយទឹកដ៏ស្អាតផង។” (ហេព្រើរ ១០:២២ គគខ)

## ចិត្តស្លូតបូត πραΰτης

**ភាពឱនលំទោន ផ្អែមល្ហែម អនុគ្រោះ ភាពទន់ភ្លន់ សេចក្ដីគោរព**

“ចូររំឭកគេឲ្យ...ប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ មិនត្រូវនិយាយអាក្រក់ពីអ្នកណា ឬឈ្លោះប្រកែកឡើយ ត្រូវមាន**ចិត្តស្លូតបូត** ទាំងសំដែងសេចក្ដីសុភាពគ្រប់យ៉ាង ដល់មនុស្សទាំងអស់ផង។”
(ទីតុស ៣:១-២ គគខ)

## ការគ្រប់គ្រងចិត្ត ἐγκράτεια

**ការចេះគ្រប់គ្រងលើចិត្ត ឬអារម្មណ៍ ចិត្តស្ងប់ស្ងាត់**

“តបន្ថែម**ការគ្រប់គ្រងចិត្ត**ទៅលើការស្គាល់ព្រះជាម្ចាស់ បន្ថែមការអត់ធ្មត់ទៅលើការគ្រប់គ្រងចិត្ត បន្ថែមការគោរពកោតខ្លាចព្រះជាម្ចាស់ទៅលើការអត់ធ្មត់។” (២ពេត្រុស ១:៦ គគខ)

CHALLIES.com

ផ្លូវពិត plovpit.com